**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង ព្រហ្មទណ្ឌ
លេខៈ៣៤
ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០
**សាលដីកា**
លេខៈ៦១
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............. ជាប្រធាន
២-លោក ................ ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............. ជាចៅក្រម
៥-លោក ................ ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
-លោក ...............

**តំណាងមហាអយ្យការ**
-ឯកឧត្តម ................ ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៣៤ ចុះថ្ងៃ របស់តុលាការកំពូល ។

**ពីបទ** បើកបររថយន្ត ខ្វះការប្រុងប្រយ័ត្ន បណ្តាលឲ្យមានការគ្រោះថ្នាក់ចរាចរ ។ ប្រព្រឹត្តនៅ ផ្លូវជាតិលេខ៤ ឃុំរកា ស្រុកច្បារមន ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ បទល្មើសដែលមានបញ្ញាត្តិឲ្យផ្តន្ទាទោស តាមមាត្រា៦១ និង១២៦ នៃច្បាប់ចរាចរផ្លូវគោក ដែលប្រកាសឲ្យប្រើតាមក្រិត្យច្បាប់លេខ៣៨ក.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ។

-ជនជាប់ចោទឈ្មោះ សសរ ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ "ស្លាប់រំលត់បណ្តឹងអាជ្ញា" មុខរបរបើកបររថយន្ត ។

-ម្ចាស់រថយន្តឈ្មោះ វថ (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរលក់គ្រឿងដែក មានទីលំនៅភូមិ ពាណិជ្ជកម្ម ឃុំរកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។
ឪពុកឈ្មោះសួរ គ្រួយ "ស" ម្តាយឈ្មោះលាង ហាក់ "រ" ប្រពន្ធឈ្មោះចៃ ហ្គិចគាវ មានកូន៤នាក់ ។ ទោសពីមុនគ្មាន ។ មេធាវីគ្មាន ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ទសជ (ចុងបណ្តឹងសាទុខក្ខ) ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មានទីលំនៅកែង ផ្លូវ២១៧ និង៦៧ សង្កាត់ផ្សារថ្មី២ ខណ្ឌដូចពេញ ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិឲ្យលោកសសព តំណាងអឲ្យក្រុមហ៊ុនហ្វាំហ្គីនធីងត្រែនស្ពត ។ គ្មានមេធាវី ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៩៨ របស់តំណាងក្រុមហ៊ុនភ្នំពេញហ្វហ្គីនធីងត្រែនស្ពាត

ប្តឹងម្ចាស់រថយន្តម៉ាក់ហ៊ីណូ ដែលបង្កគ្រោះថ្នាក់ដល់រថយន្ត របស់ក្រុមហ៊ុនខ្លួនបណ្តាលឲ្យខូចខាតយ៉ាងធ្ងន់កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ វេលាម៉ោង១៖៣០នាទី រថយន្តក្រុមហ៊ុនខ្លួនចេញដំណើរពីភ្នំពេញ ទៅក្រុងព្រះសីហនុ ពេលទៅដល់ចំណុចហួសផ្សារកំពង់ស្ពឺប្រហែល១គីឡូម៉ែត្រ ស្រាប់តែរថយន្តម៉ាក់ហ៊ីណូ ដឹកកំទេចថ្ម ដោយល្បឿនលឿន មកបុករថយន្តក្រុមហ៊ុនខ្លួន ដែលបើកបរប្រកាប់ស្តាំនោះ បណ្តាលឲ្យអ្នកដំណើរជិះក្នុងរថយន្តរងរបួសជាច្រើននាក់ ហេតុនេះក្រុមហ៊ុនខ្លួនសុំឲ្យម្ចាស់រថយន្ត ដែលបង្កគ្រោះថ្នាក់សងថ្លៃមិនបានធ្វើអាជីវកម្ម និងខូចខាតរថយន្ត ។

បានឃើញសេចសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តកំពង់ស្ពឺ បានធ្វើសេចក្តីសន្និដ្ឋានថាៈរថយន្តម៉ាក HNOស្ទួច ពិតជាបានបើកបរខុសច្បាប់ចរាចរពិតមែន ដោយបានបុករថយន្តម៉ាកតាតា ដែលកំពុងបើកបរប្រកាន់ស្តាំ បណ្តាលឲ្យស្លាប់ខ្លួនឯង និងខូចខាតរថយន្តម៉ាកតាតា និងរបួសដល់អ្នកដែលជិះលើរថយន្តនោះជាច្រើនអ្នកទៀតផង ។ ហេតុនេះ សូមតុលាការសម្រេចទៅតាមច្បាប់ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៥៩ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅ :

១-រំលត់បណ្តឹងអាជ្ញាលើឈ្មោះ សសរ អាយុ៣២ឆ្នាំ ភេទប្រុស របរបើកបររថយន្ត បានជាប់ចោទពីបទ បើកបររថយន្ត ខ្វះការប្រុងប្រយ័ត្ន បណ្តាលឲ្យបុកគ្នា និងអ្នកជិះរងរបួសអាក់ខាន ប្រកបការងារមួយរយៈ និងស្លាប់ខ្លួនឯង ប្រព្រឹត្តនៅ កំណាត់ផ្លូវជាតិលេខ៤ ត្រង់ចំណុចវិទ្យាល័យ សុខាធិល្លីក្នុងឃុំកាធំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ កាល ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៩៨ វេលាម៉ោង១១៖៣០នាទី ។

២-ឲ្យឈ្មោះវថ ម្ចាស់រថយន្ត Hino សងប្រាក់ថ្លៃជួសជុលរថយន្ត(ម៉ាកតាតាចំនួនស្មើ និង២៥០០ដុល្លាឲ្យទៅឈ្មោះទសជ(TEO SIEW CHING) តំណាងឲ្យក្រុមហ៊ុន ភ្នំពេញ ហ្វាំហ្គីនធីនត្រែនស្ពត ចាប់ពីថ្ងៃនេះតទៅសំណើលើសពីនេះត្រូវបដិសេធចោល ។

-ឲ្យសងប្រាក់ថ្លៃពលកម្មឲ្យម្ចាស់រថយន្តម៉ាកតាតាក្នុងរយៈពេលមានគ្រោះថ្នាក់ចាប់តាំងថ្ងៃទី១៥-៩-៩៨ រហូតដល់ថ្ងៃប្រកាសសាលក្រមនេះ គិតជាប្រាក់ក្នុង១ថ្ងៃ១០ម៉ឺនរៀល សំណើលើសពីនេះ ត្រូវបដិសេធចោល ចាប់តាំងពីថ្ងៃនេះតទៅ ។

-ឲ្យសងប្រាក់ថ្លៃព្យាបាលអ្នករបួសដែលជិះក្នុងរថយន្តម៉ាកតាតា ដែលមានពាក្យបណ្តឹងសុំ និងលិខិត ព្យាបាលរបស់មន្ទីរពេទ្យត្រឹមត្រូវ ។ តាមមាត្រា៦១ នៃច្បាប់ចរាចរផ្លូវគោក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩១ និងមាត្រា១២៦ នៃក្រឹត្យច្បាប់លេខ៣៨ ក្រច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំម១៩៨៨ ។

៣-សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្តី និងបើកផ្លូវឲ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះវ៉េង ថុង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥៩ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ស្ពឺត្រង់ចំណុចទី៣ វាក្យខ័ណ្ឌទី១។

បានឃើញសេចក្តីសន្និដ្ឋានរបស់មហាអយ្យការ អមសាសាឧទ្ធរណ៍ថាៈ មិនទទួលជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៩ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឈ្មោះវថ ដោយបណ្តឹងហួសកំណាត់ច្បាប់ ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារ នៃសេចក្តីសម្រេច ដូចតទៅ:

១-មិនទទួលជំនុំជំរះ លើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៩ របស់ឈ្មោះវថ ។

២-សម្រេចចំណាយរឿងព្រហ្មទណ្ឌលេខ១៤២ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ របស់ សាលាឧទ្ធរណ៍ ។

សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខវថ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវសាទុក្ខក្នុងកំណាត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះវថ ប្តឹងមិនសុខចិត្ត នឹងសាលដីកព្រហ្មទណ្ឌលេខ២១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល។

បានឃើញសារណាការពារ និងឆ្លើយតប ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០០ របស់លោក វថ

បានឃើញសារណាការពារ និងឆ្លើយតប ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ របស់លោក ទសជ

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល បានសម្រេចថាៈ បណ្តឹងឧទ្ធរណ៍របស់ឈ្មោះវថ បានហួសកាលកំណត់ច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចទៅតាមច្បាប់ ។

បានស្តាប់ចម្លើយ អះអាងនាពេលសវនាការ របស់ឈ្មោះវថ ( ម្ចាស់រថយន្ត ) បានឆ្លើយថាៈ ខ្ញុំបាទឈ្មោះវថ សូមឆ្លើយបញ្ជាក់ថាៈ ចំពោះគ្រោះថ្នាក់ចរាចរ ដែលបានកើតឡើង រវាងរថយន្តក្រុងម៉ាកតាតា របស់ក្រុមហ៊ុនហ្វាំហ្គីនធីងត្រែនស្លត និងរថយន្តម៉ាកហ៊ីណ្ឌ នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ១៩៩៨ នោះ គឺឈ្មោះសសរ ជាអ្នកជួលរថយន្តរបស់ខ្ញុំបាទ យកទៅធ្វើ អាជីវកម្មផ្ទាល់ ខ្លួនក្នុងតម្លៃប១ខែ២០០$ដុល្លាអាមេរិក ដោយមានកិច្ចសន្យាត្រឹមត្រូវ ដូច្នេះរាល់សំណងផ្សេងៗ ត្រូវឈ្មោះសសរ ជាអ្នកទទួលខុសត្រូវ ។

ការដែលតុលាការខេត្តកំពង់ស្ពឺ រំលត់បណ្តឹងអាជ្ញាលើឈ្មោះសសរ ហើយបង្វែរការទទួលខុសត្រូវលើសំណង មកលើខ្ញុំបាទនោះ ជាការពុំត្រឹមត្រូវទេ ព្រោះថ្វីត្បិតតែឈ្មោះ សសរ បានស្លាប់ក៏ពិតមែន តែបងប្អូនសាច់ញាតិ របស់អ្នកស្លាប់នៅរស់ ។

ចុងក្រោយខ្ញុំបាទ សូមសំណូមពរ ដល់ក្រុមប្រឹក្សាជំនុំជំរះ មេត្តាលើកយកបណ្តឹងសាទុក្ខរបស់ខ្ញុំបាទមកពិចារណា និងធ្វើការអង្កេតឲ្យបានត្រឹមត្រូវ ។ និងសូមឲ្យតុលាការ ពិនិត្យពិចារណាលើសំណង់ឡើងវិញ ។

បានស្តាប់ចម្លើយ អះអាងនាពេលសវនាការ របស់ឈ្មោះ សសព បានឆ្លើយថាៈ ខ្ញុំបាទឈ្មោះសសព សូមឆ្លើយបញ្ជាក់ថា៖ ចំពោះគ្រោះថ្នាក់នេះ គឺបណ្តាលមកពី អ្នកបើកបររថយន្តម៉ាកហ៊ីណ្ឌ បើកបរ មិនគោរពច្បាប់ ដោយដឹងថានៅពីមុខរថយន្តរបស់ខ្លួនមានឧបសគ្គនៅ តែបើកវ៉ាបំពានលើចំណែកផ្លូវ ដែលកំពុងធ្វើដំណើរច្រាសទិសគ្នា ។ ជាហេតុធ្វើអោយមានគ្រោះថ្នាក់ កើតឡើងបណ្តាលឲ្យ រថយន្ត ក្រុងម៉ាកតាតា ខូចខាតជាទម្ងន់ និងអ្នកជិះលើរថយន្តមានភ្ញៀវជាតិ អន្តរជាតិទទួលលរងរបួសជាទម្ងន់។ ចុងក្រោយ ខ្ញុំបាទសូមសំណូមពរ

-ទាមទារថ្លៃជួសជុលរថយន្ត និងថ្លៃបង់ខាតការរកស៊ីចំនួន៩២៦៧ដុល្លា

-សុំឲ្យចេញថ្លៃព្យាបាលអ្នករបួសទាំងអស់ ។ សុំបដិសេធសាលដីកាលេខ២១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ ទាំងស្រុង ។

-បានស្តាប់តំណាងមហាអយ្យការថាៈ ពុំមានយោបល់អ្វីបន្ថែមទៀតទេ សូមរក្សាសេចក្តីសន្និដ្ឋាននៅ ដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យករ

-ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់លោក វថ និងចម្លើយដោះសារ របស់លោក សសព ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ១៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះ វថ និងបណ្ដឹងសាទុក្ខលេខ៣០ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ របស់ឈ្មោះ ទសថ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបាន ដោយយោងតាមមាត្រ១៤ នៃច្បាប់ស្ដីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្ដី ។

-យល់ឃើញថា លោកវថ បានប្ដឹងឧទ្ធរណ៍ហួសកាលកំណត់ នៃច្បាប់ពិតមែន ដូច្នេះតាមមាត្រា៧ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី សាលាឧទ្ធរណ៍ពុំមានសមត្ថកិច្ចលើកបណ្ដឹងឧទ្ធរណ៍នេះ មកជំនុំជំរះបានឡើយ ។

-យល់ឃើញថា លោក ទសថពុំបានប្ដឹងឧទ្ធរណ៍ពីសាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺទេ ធ្វើឲ្យសាលក្រមនេះចូលជាស្ថាពរ ទៅហើយ ដូច្នេះបណ្ដឹងសាទុក្ខរបស់លោក ពុំអាចឲ្យតុលាការ កំពូល ពិនិត្យឡើងវិញ លើសាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺ បានឡើយ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១២ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ សម្រេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ ហើយ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្ដី ចំពោះមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

១-ទទួបណ្ដឹងសាទុក្ខលេខ១៤ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០០ របស់ឈ្មោះវថ និងបណ្ដឹងនិងបណ្ដឹងសាទុក្ខលេខ៣០ ចុះថ្ងៃទី០៤ខមសា ឆ្នាំ២០០០ របស់លោកទសថទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេច១២ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០០ ។